# ជំពូកទី៥ : លទ្ធផលនៃការស្រាវជ្រាវ

## ក- ធនធានរូបសាស្ត្រ

**១០៩.** ដីនេះស្ថិតនៅតំបន់វាលទំនាបភាគខាងកើតទន្លេមេគង្គនៃប្រទេសកម្ពុជា ទទួលរបបទឹកភ្លៀងជាមធ្យម ១,៦៩៨ម.ម សីតុណ្ហភាពមធ្យមប្រចាំឆ្នាំខ្ពស់ជាង២៦,៧៥ដឺក្រេសែលស៊ុស ដែលរដូវប្រាំងមានរយៈពេលវែងជាង ៤ខែ (DANIDA, 2003)។ តាមការសិក្សាទៅលើកំពស់ទឹកភ្លៀងដែលបានមកពីស្ថានីយ៍ឧតុនិយមពោធិ៍គុង នៅក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ(១៩៩៨-២០០៧) បានអោយដឹងថា មធ្យមភាគ កំពស់ទឹកភ្លៀងប្រចាំឆ្នាំមានការប្រែប្រួលក្នុងចន្លោះពី ១៤៦៨.៣-២៥៤៩.២ ម.ម (ឧបសម្ព័ន្ធទី ៥-២)។

**១១០.** យោងតាមផែនទីរយៈកំពស់ដី បង្ហាញថារយៈកំពស់មានការប្រែប្រួល (១) 0-២០ (២) ២០-៤០ (៣)៤០-៦០ (៤)៦០-៨០ និង(៥)៨០-១០០ ដូច្នេះយើងឃើញថា វាស្ថិតនៅចន្លោះពី 0-១០០ ម៉ែត្រ ប្រៀបធៀបនឹងនីវ៉ូទឹកសមុទ្រ (ឧបសម្ព័ន្ធ៥-១ : ផែនទី១ ផែនទីរយៈកំពស់ដី)។

**១១១.** ដីជាតិដីអាចកំណត់ដោយសិលាមេដែលមានស្ថិតនៅស្រទាប់ក្រោម។ លក្ខណៈគីមីរបស់ដីតែងតែបញ្ជាក់អំពីកំរិត និងលំនាំនៃការបំបែកធាតុរបស់សិលាមេក្នុងយុគសម័យភូគព្ភសាស្ត្រ និងលក្ខណៈរបស់ថ្មដែលជាសិលាមេ។ ដំណើរប្រព្រឹត្តទៅនៃបាតុភូតភូគព្ភសាស្ត្រនេះបានទទួលរងនូវឥទ្ធិពលអាកាសធាតុ ពេលវេលា ឋានលេខា និងដំណើរប្រព្រឹត្តទៅតាមលក្ខណៈជីវសាស្ត្រធម្មជាតិ លក្ខណៈជីវសាស្ត្រដែលបង្កឡើងដោយមនុស្ស សត្វ និងបាក់តេរី ។ កត្តាទាំងអស់នេះអាចបញ្ជាក់ដោយផ្ទាល់ និងដោយប្រយោលអំពីដីដែលមានលក្ខណៈជាអាស៊ីត ពណ៌ រចនាសម្ព័ន្ធ ជីជាតិ លទ្ធភាពផលិតកម្ម និងភាពជ្រាបទឹក។ យោងតាមផែនទីភូគព្ភសាស្ត្រ (ឧបសម្ព័ន្ធ ៥-១:ផែនទី២) បង្ហាញថាដី សម្បទានមានសិលាមេ៦ប្រភេទ:

តារាង ៥-១: បង្ហាញស្ថានភាពសិលាមេ

| ល.រ | ប្រភេទសិលាមេ | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|---|
| ១ | Andesite,andesitic breccia and tuff | ៨២ | ៤ |
| ២ | Calcareous rocks | ២៣០ | ១១,២២ |
| ៣ | Diorite | ១៥១ | ៧,៣៧ |

Draft

| | | | |
|---|---|---|---|
| ៤ | Formation(sandstone and micro-breccia) | ១៤៦៥ | ៧១.៤៦ |
| ៥ | Hornfels,meta-arkose and meta-andesite | ៥២ | ២.៥៤ |
| ៦ | Rhyolite | ៧០ | ៣.៤១ |
| សរុប | | ២០៥០ | ១០០ |

១១២. យោងតាមលក្ខណៈដី និងឋានលេខា និងផែនទីចំណាត់ថ្នាក់ប្រភេទដី (ឧបសម្ព័ន្ធ៥-១:ផែនទី៣) នៅតំបន់ស្រាវជ្រាវ និងរុករករ៉ែនេះគ្របដណ្តប់ទៅដោយដី ០១ប្រភេទគឺៈ

**តារាង ៥-២: បង្ហាញចំណាត់ថ្នាក់ប្រភេទដី**

| ល.រ | ចំណាត់ថ្នាក់ប្រភេទដី | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|---|
| ១ | Plinthite podzols | ២០៥០ | ១០០ |
| សរុប | | ២០៥០ | ១០០ |

១១៣. យោងតាមចំណាត់ប្រភេទគុណភាពរបស់ដីនៅក្នុងតំបន់សម្បទានទាំងមូលមាន ០១ប្រភេទគឺ ដីមានជីជាតិទាប (Low productivity soil) មានទំហំ ២០៥០ហិកតា ឬស្មើនឹង ១០០ ភាគរយ លាតសន្ធឹងនៅពាសពេញនៃតំបន់សម្បទាន (ឧបសម្ព័ន្ធ៥-១ : ផែនទី៤ ផែនទីចំណាត់ថ្នាក់ជីជាតិដី) ។

**តារាង ៥-៣: បង្ហាញចំណាត់ថ្នាក់ប្រភេទជីជាតិដី**

| ល.រ | ចំណាត់ថ្នាក់ប្រភេទជីជាតិដី | ផ្ទៃដី (ហិកតា) | ភាគរយ |
|---|---|---|---|
| ១ | Low productivity soil | ២០៥០ | ១០០ |
| សរុប | | ២០៥០ | ១០០ |

១១៤. តាមរយៈការសិក្សាទៅលើលក្ខណៈរបស់ឋានលេខា និងចំណាត់ថ្នាក់ទីជំរាល (ឧបសម្ព័ន្ធ៥-១:ផែនទី៥) បង្ហាញអោយឃើញថា សណ្ឋានដីមានសភាពប្រែប្រួលជាមួយនឹងចំណាត់ថ្នាក់ទីជំរាលបីប្រភេទគឺៈ

- ចំណោត់ថ្នាក់ធំជាង ៥ដឺក្រេ: ដីសម្បទានតំបន់នេះមានដីជំរាលចំណោត់ថ្នាក់ធំជាង ៥ដឺក្រេ មានចំនួន ៥ ហិកតា ឬស្មើនឹង ០,២៤ភាគរយនៃផ្ទៃដីសរុប ដីតំបន់នេះមានលក្ខណៈចោតបន្តិចម្តងៗ ហើយសណ្ឋានដី មានលក្ខណៈជ្រោះ។ សណ្ឋានដីប្រភេទនេះជានិច្ចជាកាលតែងជួបប្រទះនៅតាមតំបន់ខ្ពង់រាប។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ ហើយធន់ នឹងការហូរច្រោះជាងចំណោត់ថ្នាក់ទី១ខាងលើ។ ការប្រើប្រាស់ដីតំបន់នេះអាចមានលក្ខណៈជាការដាំឈើ បែបផែនពាណិជ្ជកម្ម វាលស្មៅ និងការដាំរួមរវាងឈើ និងដំណាំកសិកម្ម ប្រសិនបើអនុវត្តវិធានការណ៍ អភិរក្សបានត្រឹមត្រូវ។

- ចំណោត់ថ្នាក់ ២-៥ដឺក្រេ: ដីសម្បទានតំបន់នេះមានដីជំរាលចំណោត់ថ្នាក់២-៥ដឺក្រេ ចំនួន២៥ហិកតា ឬ ស្មើនឹង១,២២ភាគរយនៃផ្ទៃដីសរុប។ ដីតំបន់នេះមានលក្ខណៈស្មើររាបស្មើ មិនមានតម្រូវការនៃការអភិរក្សទឹក និងដីទេ។ តាមទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជម្រាលប្រភេទនេះ ការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ។ ដីតំបន់នេះអាចប្រើប្រាស់សម្រាប់កសិកម្ម និងព្រៃឈើ។

- ចំណោត់ថ្នាក់ ០-២ដឺក្រេ: ដីសម្បទានតំបន់នេះមានដីជំរាលចំណោត់ថ្នាក់០-២ដឺក្រេ ចំនួន២០២០ ហិកតា ឬស្មើនឹង ៩៨,៥៤ភាគរយនៃផ្ទៃដីសរុប ជាដីរាបស្មើ។ ផ្អែកលើទស្សនៈនៃការអភិរក្សទឹក និងដីនៅតំបន់ទីជំរាល ប្រភេទនេះការប្រើប្រាស់ដីមានលក្ខណៈទូលំទូលាយ។ ដីតំបន់នេះអាចប្រើប្រាស់សំរាប់ដំណាំស្រូវ ដំណាំកសិកម្ម និងព្រៃឈើ។

**១១៥.** តាមការសង្កេតដោយរហ័សរបស់ក្រុមស្រាវជ្រាវបានបង្ហាញថា ជាទូទៅប្រភេទដីនៅតំបន់រុករករ៉ែរបស់ក្រុមហ៊ុន XING YUAN KANNG YEAK Co., Ltd. ជាប្រភេទដី ល្បាយខ្សាច់លាយគ្រួស និង ថ្មនៅតំបន់ជិតមាត់ទឹក និងបាតអូរជាប្រភេទដីមានដីជាតិបង្គួរ ដោយសារដីនេះព័ទ្ធជុំវិញដោយតំបន់ខ្ពង់រាបមានល្បាប់ហូរ នៅរាល់រដូវវស្សាដីឥដ្ឋប្រផេះរបាយខ្សាច់មានថ្មផុសដោយកន្លែង ជាពិសេសតាមដងអូរ ដីឥដ្ឋលាយថ្ម ដោយកន្លែងដែលជាប្រភេទដីមានដីជាតិមធ្យមសំរាប់ដំណាំកសិឧស្សាហកម្ម។

**១១៦.** ដីសំរាប់ដំណាំកសិកម្មដែលក្រុមស្រាវជ្រាវបានជួបប្រទះមាននៅក្បែរអូរ ដែលជាតំបន់ព្រៃល្បោះ ចំណែកដីនៅតាមព្រៃពាក់កណ្តាលស្រោង ជាដីល្បាយខ្សាច់ពណ៌ប្រផេះកន្លែងខ្លះ មានពណ៌ក្រម៉ៅតែមានថ្មច្រើន។ រចនាសម្ព័ន្ធថ្នាក់ក្រោមជាប្រភេទ ស្មៅព្រិច និងកូនឈើតូចៗ ប៉ុន្តែនៅពេលចុះពិនិត្យអង្កេត រចនាសម្ព័ន្ធស្រទាប់ក្រោមត្រូវភ្លើងឆេះអស់ មិនទាន់ដុះឡើងវិញទេ។

**១១៧.** តំបន់សម្បទានរ៉ែនេះគ្មានប្រភពទឹកស្រទាប់លើច្រើនទេ។ មានអូរតូច១០២ ដែលអូរទី-១ (អូររាម) (អូរនេះមានទឹកតែនៅពេលភ្លៀងប៉ុណ្ណោះ) ហូរចេញពីទីតាំង ដែលក្រុមហ៊ុនគ្រោងសាងសង់ស្នាក់ការមេ



Draft

និងប្រព័ន្ធចង្វាក់ផលិតកម្ម ឆ្ពោះទៅទិសពាយ័ព្យចម្ងាយប្រមាណ ១៥គ.ម មុនធ្លាក់ចូលទៅក្នុងអូរតាលើង នៅចំណុចស្ពានអូរតាលើង មុនបន្តហូរចុះទៅក្រោមដែលមានចម្ងាយប្រមាណ ២៥គ.ម ហើយ ចាក់ចូលទៅក្នុងទន្លេមេគង្គ នៅត្រង់ម្តុំកោះខ្មែរ។ អូរទី-២ មានឈ្មោះហៅថា អូរថ្ម (អូរនេះមានទឹកតែនៅពេលភ្លៀងប៉ុណ្ណោះ)។ អូរនេះហូរចេញពីម្តុំរណ្តៅរ៉ែទី-១ ទៅទិសខាងកើតចម្ងាយប្រមាណ០៤គ.ម ហើយសំដៅមកទិសខាងត្បូងប្រមាណ ១២គ.ម ទើបធ្លាក់ចូលអូរខ្ជិកខ្លក់។ ពីចំណុចនេះមកដល់ព្រែក កាំពី មានចម្ងាយប្រមាណ ២២គ.ម ហើយទើបបន្តធ្លាក់ចុះតាមព្រែកកាំពី ចម្ងាយប្រមាណ៣៥គ.ម ទៀត ទើបធ្លាក់ចុះទៅក្នុងទន្លេមេគង្គ នៅត្រង់រមណីយដ្ឋានព្រែកកាំពី។ ប្រជាជននៅក្នុងតំបន់នេះអាចប្រើប្រាស់ទឹកស្រទាប់លើតែនៅក្នុងរដូវវស្សាប៉ុណ្ណោះ។ តែនៅរដូវប្រាំងត្រូវទិញទឹកពីខាងក្រៅ (ដឹកមកពីទន្លេ) ព្រោះប្រភពទាំងនោះត្រូវរីងស្ងួតនៅត្រឹមពាក់កណ្តាលខែវិច្ឆិការ។ ក្នុងតំបន់នេះគ្មានអណ្តូងទេ ព្រោះជីកមិនចេញ (គ្មានប្រភពទឹកក្រោមដី)។

១១៨. ការប្រើប្រាស់ដីនៅតាមបណ្តោយផ្លូវចូលទៅកាន់តំបន់រ៉ែមានមួយប្រភេទគឺៈ ដីស្រែ ដែលភាគច្រើនប្រើសំរាប់ធ្វើស្រូវវស្សាតែធ្វើតែមួយរដូវប៉ុណ្ណោះ បន្ទាប់ពីប្រមូលផលស្រូវហើយដីនឹងនៅទំនេររហូតដល់រដូវបង្កបង្កើនផលឆ្នាំក្រោយ។

**១១៩. ការយកសំណាកទឹក និងការវិភាគៈ** ក្រុមការងារបានយកសំណាកទឹកចំនួន ០៤សំណាក កាលពីថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ២០១១ គឺ សំណាកទី-១ៈ យកពីអូរខ្ជិកខ្លក់ ដែលមានចំណុចនិយាមកា ៦៤៤១៤៧-១៤១១០០០ សំណាកទី-២ៈ យកពីទឹកអណ្តូងនៅតំបន់អូរធំ ដែលមានចំណុចនិយាមកា ៦៤០៨៦០-១៤១៣៨៧៧ សំណាកទី-៣ៈ យកពីទឹកអណ្តូងក្នុងភូមិអូរពោធិ៍ ដែលមានចំណុចនិយាមកា ៦២៧៦១០-១៤១៦៤៩៨ និងសំណាកទី-៤ៈ យកពីទឹកប្រើប្រាស់ក្នុងភូមិត្រួន ដែលមានចំណុចនិយាមកា ៦៣៨៨៧៨-១៤១៣៩៥០ ដើម្បីធ្វើការវិភាគអំពីលក្ខណៈរូប និងលក្ខណៈគីមី។ សំណាកទាំងបួននេះត្រូវបានបញ្ជូនទៅមន្ទីរពិសោធន៍របស់ក្រសួងដើម្បីធ្វើការវិភាគ (ឧបសម្ព័ន្ធ៥-៣ៈ **លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថាន**)។

**១២០. សំណាកទី-១ៈ** តាមរយៈការវិភាគលទ្ធផលវិភាគទឹក ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន រួចមកបង្ហាញថា **(១) លក្ខណៈរូប** - នៅក្នុងចំណោមថាវ៉ូបបន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននៅក្នុងសំណាកទី-១ នេះ មានខ្ពស់ជាងកំរិតស្តង់ដាររបស់ទឹក ដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់របស់ក្រសួងបរិស្ថាន និងអង្គការសុខភាពពិភពលោក ពោលគឺ ៣C/១០ ចំពោះ Total Coliform និង ១២៧/១០០ ចំពោះ Total Bacteria និង **(២) លក្ខណៈគីមី** - នៅក្នុងចំណោមថាវ៉ូបទាំង ២០ មាន ថាវ៉ូបចំនួន០៤ ក្នុងនោះមាន០៣ជា Trace Metals (Nickel –ND< 0.0005mg/l, Cobalt – 0.0007 mg/l and Mercury – 0.0006mg/l) ចំណែកគុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែនវិញមានត្រឹមតែ pH = ៧.០៤ តែប៉ុណ្ណោះ ពោលគឺត្រូវនឹងកំរិតស្តង់ដារពី ៦.៥-៧.៥។ ការវិភាគពីកត្តាចំណីរបស់ទឹកជាធម្មតា គឺត្រូវ

Draft

ផ្តោត ជាសំខាន់ទៅលើអង្គធាតុសំខាន់ចំនួន០២ ដែលចាំបាច់សម្រាប់រុក្ខជាតិ និងវីរជាតិគឺ អាសូត និងហ្វូស្វ័រ នៅក្នុងទម្រង់ជានីត្រាត - $NO_3^-$ និងអ៊ីយ៉ុងហ្វូស្វាត - $PO_4^{3-}$ ទោះបីជានៅក្នុងលទ្ធផលវិភាគទឹករបស់ក្រសួងមិនបានបង្ហាញ ពីវត្តមានរបស់អ៊ីយ៉ុងហ្វូស្វាត-$PO_4^{3-}$ តែបរិមាណនីត្រាតដែលមាននៅក្នុងទឹកនេះមានតែ ND<0.១ មីលីក្រាមប៉ុណ្ណោះ ពោលគឺទាបជាងកំរិតស្តង់ដាររហូតដល់ទៅ ៣០ដងឯណោះ ។ ចំណែកឯថាវរូបចំនួន១៥ ផ្សេងទៀត មិនមានអ្វីគួរអោយធ្វើការកត់សំគាល់ទេ (**ឧបសម្ព័ន្ធ៥-៣ : តារាង១ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថាន**) ។

**១២១. សំណាកទី-២:** តាមរយៈការវិភាគលទ្ធផលវិភាគទឹក ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន រួចមកបង្ហាញថា (១) **លក្ខណៈរូប** - នៅក្នុងចំណោមថាវរូបបន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននៅក្នុងសំណាកទី-២ នេះ មានខ្ពស់ជាងកំរិតស្តង់ដាររបស់ទឹក ដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់របស់ក្រសួងបរិស្ថាន និងអង្គការសុខភាពពិភពលោក ពោលគឺ ៣០/១០ ចំពោះ Total Coliform និង ១០១/១០០ ចំពោះ Total Bacteria និង (២) **លក្ខណៈគីមី** - នៅក្នុងចំណោមថាវរូបទាំង ២០ មានថាវរូបបន្ត ចំនួន០៤ ក្នុងនោះមាន០៣ជា Trace Metals (Nickel –ND< 0.0004mg/l, Cobalt –0.0006mg/l and Mercury –ND< 0.0005mg/l) ចំណែកតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែនវិញមានត្រឹមតែ pH = 6.69 តែប៉ុណ្ណោះ ពោលគឺ ត្រូវនឹងកំរិតស្តង់ដារពី ៦,៥-៧,៥ ។ ការវិភាគពីកត្តាចំណីរបស់ទឹកជាធម្មតា គឺត្រូវផ្តោតជាសំខាន់ទៅលើអង្គធាតុសំខាន់ ចំនួន០២ ដែលចាំបាច់សម្រាប់រុក្ខជាតិ និងវីរជាតិគឺ អាសូត និងហ្វូស្វ័រ នៅក្នុងទម្រង់ជានីត្រាត - $NO_3^-$ និងអ៊ីយ៉ុង ហ្វូស្វាត - $PO_4^{3-}$ ទោះបីជានៅក្នុងលទ្ធផលវិភាគទឹករបស់ក្រសួងមិនបានបង្ហាញពីវត្តមានរបស់អ៊ីយ៉ុងហ្វូស្វាត - $PO_4^{3-}$ តែបរិមាណនីត្រាតដែលមាននៅក្នុងទឹកនេះមានតែ ០.១០ មីលីក្រាមប៉ុណ្ណោះ ពោលគឺទាបជាងកំរិតស្តង់ដាររហូតដល់ទៅ ៣០ដងឯណោះ ។ ចំណែកឯថាវរូបចំនួន១៥ ផ្សេងទៀត មិនមានអ្វីគួរអោយធ្វើការកត់សំគាល់ទេ (**ឧបសម្ព័ន្ធ៥-៣: តារាង២ លទ្ធផលវិភាគទឹករបស់ក្រសួង បរិស្ថាន**) ។

**១២២. សំណាកទី-៣:** តាមរយៈការវិភាគលទ្ធផលវិភាគទឹក ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន រួចមកបង្ហាញថា (១) **លក្ខណៈរូប** - នៅក្នុងចំណោមថាវរូបបន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននៅក្នុងសំណាកទី-៣ នេះ មានទាបជាងកំរិតស្តង់ដាររបស់ទឹក ដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់របស់ក្រសួងបរិស្ថាន និងអង្គការសុខភាពពិភពលោក ពោលគឺ ០/១០ ចំពោះ Total Coliform និង ៣៨/១០០ ចំពោះ Total Bacteria និង (២) **លក្ខណៈគីមី** - នៅក្នុងចំណោមថាវរូបទាំង ២០ មានថាវរូបបន្ត ចំនួន០៤ ក្នុងនោះមាន០៣ជា Trace Metals (Nickel –ND< 0.0004mg/l, Cobalt –0.0005mg/l and Mercury –ND< 0.0005mg/l) ចំណែកតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែនវិញមានត្រឹមតែ pH = 7.43 តែប៉ុណ្ណោះ ពោលគឺត្រូវនឹងកំរិតស្តង់ដារពី ៦,៥-៧,៥ ។ ការវិភាគពីកត្តាចំណីរបស់ទឹកជាធម្មតា គឺត្រូវផ្តោតជាសំខាន់ទៅលើអង្គធាតុសំខាន់ ចំនួន០២ ដែលចាំបាច់សម្រាប់រុក្ខជាតិ និងវីរជាតិគឺ អាសូត និងហ្វូស្វ័រ នៅក្នុង

Draft

ទម្រង់ជានីត្រាត - NO3- និងអ៊ីយ៉ុង ហ្វូស្វាត - $PO4^{3}$- ។ ទោះបីជានៅក្នុងលទ្ធផលវិភាគទឹករបស់ក្រសួងមិនបាន បង្ហាញពីវត្តមានរបស់អ៊ីយ៉ុងហ្វូស្វាត - $PO4^{3}$- តែបរិមាណនីត្រាតដែលមាននៅក្នុងទឹកនេះមានតែ ០,៦៧ មីលីក្រាមប៉ុណ្ណោះ ពោលគឺទាបជាងកំរិតស្តង់ដាររហូតដល់ទៅ ៨ដងឯណោះ។ ចំណែកឯថាវរូបចំនួន១៥ ផ្សេងទៀត មិនមានអ្វីគួរអោយធ្វើការកត់សំគាល់ទេ (**ឧបសម្ព័ន្ធ៥-៣: តារាង៣ លទ្ធផលវិភាគទឹករបស់ក្រសួង បរិស្ថាន**) ។

**១២៣. សំណាកទី-៤:** តាមរយៈការវិភាគលទ្ធផលវិភាគទឹក ដែលទទួលបានពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន រួចមកបង្ហាញថា (១) **លក្ខណៈរូប** - នៅក្នុងចំណោមថាវរូបបន្តចំនួនពីរគឺ Total Coliform និង Total Bacteria ដែលមានវត្តមាននៅក្នុងសំណាកទី-៤ នេះ មានទាបជាងកំរិតស្តង់ដាររបស់ទឹក ដែលត្រូវបានអនុញ្ញាតអោយប្រើប្រាស់របស់ក្រសួងបរិស្ថាន និងអង្គការសុខភាពពិភពលោក ពោលគឺ ០/១០ ចំពោះ Total Coliform ប៉ុន្តែបរិមាណរបស់ Total Bacteria បែរជាមានកំរិតខ្ពស់ជាងទៅវិញ ពោលគឺ ១១៦/១០០និង ចំពោះ Total Bacteria និង (**២**) **លក្ខណៈគីមី** - នៅក្នុងចំណោមថាវរូបទាំង ២០ មានថាវរូបបន្ត ចំនួន០៤ ក្នុងនោះមាន០៣ជា Trace Metals (Nickel –ND< 0.0008mg/l, Cobalt – 0.0007mg/l and Mercury –ND< 0.0005mg/l) ចំណែកតុល្យភាពអ៊ីយ៉ុងអ៊ីដ្រូសែនវិញមានត្រឹមតែ pH = 7.80 ពោលគឺ ខ្ពស់ជាងកំរិតស្តង់ដារពី ៦,៥-៧,៥។ ការវិភាគពីកត្តាចំណីរបស់ទឹកជាធម្មតា គឺត្រូវផ្តោតជាសំខាន់ទៅលើអង្គធាតុសំខាន់ចំនួន០២ ដែលចាំបាច់សម្រាប់រុក្ខជាតិ និងវីរជាតិគឺ អាសូត និងហ្វូស្វ័រ នៅក្នុង ទម្រង់ជានីត្រាត - $NO_3$- និងអ៊ីយ៉ុង ហ្វូស្វាត - $PO4^{3}$- ។ ទោះបីជានៅក្នុងលទ្ធផលវិភាគទឹករបស់ក្រសួងមិនបាន បង្ហាញពីវត្តមានរបស់អ៊ីយ៉ុងហ្វូស្វាត - $PO_4^{3}$- តែបរិមាណនីត្រាតដែលមាននៅក្នុងទឹកនេះមានតែ ០,១១ មីលីក្រាមប៉ុណ្ណោះ ពោលគឺទាបជាងកំរិតស្តង់ដាររហូតដល់ទៅ ២៧ដងឯណោះ។ ចំណែកឯថាវរូបចំនួន១៥ ផ្សេងទៀត មិនមានអ្វីគួរអោយធ្វើការកត់សំគាល់ទេ (**ឧបសម្ព័ន្ធ៥-៣: តារាង៤ លទ្ធផលវិភាគទឹករបស់ក្រសួងបរិស្ថាន**) ។

## ខ- ធនធានអេកូឡូស៊ី

**១២៤.** សារព័ន្ធព្រៃឈើនៅលើទីតាំងស្នើសុំរបស់ក្រុមហ៊ុន XING YUAN KANNG YEAK Co.,Ltd. បានកើតមានឡើងដោយសារប្រភេទសារព័ន្ធរុក្ខជាតិសំខាន់ៗ។ កំណើតដើមនៃប្រភេទព្រៃទាំងនេះអាស្រ័យទៅនឹងអាកាសធាតុរបស់តំបន់លក្ខណៈភូមិសាស្ត្រសណ្ឋានដី និងសមាសភាពនៃប្រភេទឈើ ហើយប្រភេទព្រៃសំខាន់ៗទាំងនេះបានកើតឡើងដោយសារអនុប្រភេទជាច្រើនទៀត។ ឯកសារយោងដែលបានប្រើនៅក្នុងរយៈពេលនៃការសិក្សា និងអង្កេតដែលធ្វើឡើងក្នុងតំបន់នេះ តាមរូបភាពផ្កាយរណបឆ្នាំ ១៩៩២-១៩៩៣, ១៩៩៧, ២០០២ និង ២០០៦ របស់ UNDP GIS Dataset និងរដ្ឋបាលព្រៃឈើ (**ឧបសម្ព័ន្ធ៥-១ : ផែនទី ៦-៩ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) ។ នៅក្នុងរយៈពេលនៃការវាយតំលៃជាក់ស្តែងអំពីតំលៃអេកូឡូស៊ី និង តំលៃពាណិជ្ជកម្មរបស់ព្រៃបានបញ្ជាក់ថា ស្ថានភាពអេកូឡូស៊ីនៅក្នុងតំបន់នេះត្រូវបានទទួលរងការរំខានមធ្យម ចំណែកឯឈើដែលមានតំលៃពាណិជ្ជកម្មវិញ ត្រូវបានដកហូតស្ទើរតែទាំងស្រុង លើកលែងតែប្រភេទឈើ

ដែលមិនជាទីពេញនិយមសំរាប់ទីផ្សារប៉ុណ្ណោះ ដែលមាននៅសេសសល់ក្នុងតំបន់នេះ ដូចជាស្រឡៅជាដើម។ ការសិក្សា អំពីការប្រែប្រួលស្ថានភាពសារពើរុក្ខជាតិក្នុងតំបន់ស្នើសុំនេះចាប់ពីឆ្នាំ ១៩៩២ -២០០៦ បង្ហាញថា:

- ចាប់ពីឆ្នាំ១៩៩២-១៩៩៣ ក្នុងតំបន់សម្បទានទាំងមូលមានសហគមន៍សារព័ន្ធរុក្ខជាតិ ចំនួនមួយប្រភេទប៉ុណ្ណោះ គឺដីមានគំរបព្រៃ ឬអាចយល់បានថាជាព្រៃបៃតងជានិច្ច។
- ចាប់ពីឆ្នាំ១៩៩៦-១៩៩៧ ក្នុងតំបន់សម្បទានទាំងមូលមានសហគមន៍សារព័ន្ធរុក្ខជាតិចំនួនមួយប្រភេទប៉ុណ្ណោះ គឺជាដីមានគំរបព្រៃ ឬជាព្រៃបៃតងជានិច្ច។
- ចាប់ពីឆ្នាំ២០០២ ក្នុងតំបន់សម្បទានទាំងមូលមានសហគមន៍សារព័ន្ធរុក្ខជាតិ ចំនួនបីប្រភេទប៉ុណ្ណោះ គឺព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ និងដីគ្មានគំរបព្រៃ។
- ចាប់ពីឆ្នាំ២០០៦ ក្នុងតំបន់សម្បទានទាំងមូលមានសហគមន៍សារព័ន្ធរុក្ខជាតិ ចំនួនបីប្រភេទប៉ុណ្ណោះ គឺព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ និងដីគ្មានគំរបព្រៃ។

**លំនាំនៃការប្រើប្រាស់ដី**

**១២៥.** ជាច្រើនជំនាន់មកហើយរាល់សកម្មភាពសេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជាមួយផ្នែកធំ គឺផ្អែកលើបរកសិកម្ម ដែលបានប្រមូលផ្តុំនៅជុំវិញតំបន់ទំនាបទន្លេមេគង្គ។ ដំណាំកសិកម្មដែលមានគឺ: ស្រូវ កៅស៊ូ ពោត សណ្តែក កប្បាស អំពៅ ម្នាស់ និងបន្លែផ្សេងៗទៀត។ ប៉ុន្តែថ្មីៗនេះសង្កេតឃើញមានការរីកដុះដាលនូវចលនានៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច សម្បទានរ៉ែ សម្រាប់ការអភិវឌ្ឍន៍ជាច្រើន ដែលជាទិសដៅរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រជនបទ តាមរយៈការទាក់ទាញវិនិយោគិនអោយធ្វើការវិនិយោគក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ និងអភិរក្សធនធានធម្មជាតិ ដែលសម្បូរណ៍បែបនៅក្នុងប្រទេសកម្ពុជា ដោយរក្សាបាននូវចីរភាពនៃការអភិវឌ្ឍន៍។

**១២៦.** គួរអោយកត់សំគាល់ផងដែរថា ការផ្លាស់ប្តូរនូវលំនាំនៃការប្រើប្រាស់ដីនៅក្នុងប្រទេសយើង គឺកើតមានឡើងដោយសារ ហាយនភាពនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ក្នុងរយៈពេលនៃបណ្តាឆ្នាំដែលសង្គ្រាមស៊ីវិលបានអូសបន្លាយរ៉ាំរ៉ៃ ក្នុងនោះផ្ទៃដីមួយភាគធំត្រូវបានបោះបង់ចោល ហើយបន្ទាប់មកក៏ក្លាយទៅជាដីដែលគ្មានជីវជាតិ។ គ្រោះថ្នាក់ជាបន្តបន្ទាប់ដែលកើតមានឡើង ដោយមិនអាចទាយទុកបាននៃឆ្នាំមហន្តរាយធម្មជាតិ បានជំរុញអោយមានការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាជនជនបទ។ ដោយសារតែកត្តាធម្មជាតិ និងកត្តាសត្វចង្រៃ បំផ្លាញដំណាំបានធ្វើអោយការធ្វើកសិកម្មតាមតំបន់ទំនាប មានការរងសំពាធយ៉ាងធ្ងន់ធ្ងរ។

**១២៧.** នៅក្នុងបរិបទនៃការរក្សាទឹកទុកព្រៃឈើមានពហុមុខងារអេកូឡូស៊ីសំខាន់សំរាប់រុក្ខជាតិ ក្នុងការការពារ និងទប់ស្កាត់ការហូរច្រោះដី ដំណុះខ្សាច់នៅតាមបាតស្ទឹង និងប្រភពទឹកនានា និងទឹកជំនន់ក្នុងតំបន់ទំនាប។ ជាពិសេសប្រភេទព្រៃនៅតំបន់ទាំងបី រឹតតែមានសារៈសំខាន់ថែមទៀតក្នុងការជួយទប់ស្កាត់ការហូរច្រោះ។

**ស្ថានភាព និងការប្រែប្រួលរបស់គំរបព្រៃ**

**១២៨.** តាមរយៈការវិភាគអំពីការប្រែប្រួលអំពីស្ថានភាពរបស់គំរបព្រៃក្នុងតំបន់ដែនសម្បទានទាំងមូល នៅក្នុងរយៈពេល១៤ឆ្នាំ ចុងក្រោយដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យ របស់ UNDP Dataset, ១៩៩២-៩៣, ១៩៩៦-៩៧ និង FA GIS Dataset ២០០២ និង ២០០៦ បានបង្ហាញ អោយដឹងថា ស្ថានភាពគំរបព្រៃនៅទូទាំងតំបន់សម្បទានរ៉ែនេះត្រូវបានបាត់បង់អស់ចំនួន ២០៥០ហិកតា ឬស្មើនឹង ១០០ភាគរយ បើប្រៀបធៀបជាមួយនឹងផ្ទៃដីដែលមានគំរបព្រៃសរុប (ឬជាព្រៃបៃតងជានិច្ច) ។

**១២៩.** យោងតាមរូបភាពផ្កាយរណប - UNDP Dataset, ១៩៩២-១៩៩៣ (**ឧបសម្ព័ន្ធ៥-១ : ផែនទី៦ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) បានបង្ហាញថា ស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់ស្នើសុំនេះគឺ:

| | | |
|---|---|---|
| - ដីមានគំរបព្រៃ | ២០៥០ ហិកតា | = ១០០ភាគរយ |

**១៣០.** យោងតាមរូបភាពផ្កាយរណប - UNDP Dataset, ១៩៩៦-១៩៩៧ (**ឧបសម្ព័ន្ធ៥-១ : ផែនទី៧ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) បានបង្ហាញថា ស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់ស្នើសុំនេះគឺ

| | | |
|---|---|---|
| - ដីមានគំរបព្រៃ | ២០៥០ ហិកតា | = ១០០ភាគរយ |

**១៣១.** យោងតាមរូបភាពផ្កាយរណប - UNDP Dataset, ២០០២ (**ឧបសម្ព័ន្ធ៥-១ : ផែនទី៨ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) បានបង្ហាញថា ស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់ស្នើសុំនេះគឺ

| | | |
|---|---|---|
| - ព្រៃពាក់កណ្តាលស្រោង | ៩៧១ ហិកតា | = ៤៧.៣៧ភាគរយ |
| - ព្រៃល្បោះ | ១០០៥ ហិកតា | = ៤៩.៩២ភាគរយ |
| - ដីគ្មានគំរបព្រៃ | ៧៤ ហិកតា | = ៣.៦១ភាគរយ |
| សរុប | ២០៥០ ហិកតា | = ១០០ភាគរយ |

**១៣២.** យោងតាមរូបភាពផ្កាយរណប - UNDP Dataset, ២០០៦ (**ឧបសម្ព័ន្ធ៥-១ : ផែនទី៩ ផែនទីប្រើប្រាស់ដី និងគំរបព្រៃ**) បានបង្ហាញថា ស្ថានភាពគំរបព្រៃ និងការប្រើប្រាស់ដីក្នុងតំបន់ស្នើសុំនេះគឺ

| | | |
|---|---|---|
| - ព្រៃពាក់កណ្តាលស្រោង | ៩៧២ ហិកតា | = ៤៧.៤១ភាគរយ |
| - ព្រៃល្បោះ | ១០៧៦ ហិកតា | = ៥២.៤៩ភាគរយ |
| - ដីគ្មានគំរបព្រៃ | ២ ហិកតា | = ០.១០ភាគរយ |
| សរុប | ២០៥០ ហិកតា | = ១០០ភាគរយ |

**១៣៣.** យោងតាមរូបភាពផ្កាយរណប (UNDP, FA GIS Dataset, ១៩៩២-១៩៩៣, ១៩៩៦-១៩៩៧, ២០០២ និង ២០០៦ បានបង្ហាញថា ស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃនៅក្នុងតំបន់ស្នើសុំនេះ មានការប្រែប្រួលគួរអោយកត់សំគាល់ដូចខាងក្រោម ដោយក្នុងនោះសហគមន៍សារព័ន្ធរុក្ខជាតិបានកើនឡើងពីមួយប្រភេទទៅបីប្រភេទនៅឆ្នាំ២០០២ និង២០០៦ ។

Draft

**តារាង៥-៤: ការប្រែប្រួលស្ថានភាពនៃការប្រើប្រាស់ដី និងគំរបព្រៃនៅក្នុងតំបន់ស្នើសុំ**

| ប្រភេទព្រៃ | ១៩៩២-៩៣ | ១៩៩៦-៩៧ | ២០០២ | ២០០៦ |
|---|---|---|---|---|
| ដីមានគំរបព្រៃ | ២០៥០ | ២០៥០ | - | - |
| ព្រៃពាក់កណ្ដាលស្រោង | - | - | ៩៧១ | ៩៧២ |
| ព្រៃល្បោះ | - | - | ១០០៥ | ១០៧៦ |
| ដីគ្មានគំរបព្រៃ | - | - | ៧៤ | ២ |

១៣៤. តាមការពិនិត្យទៅលើផែនទីគំរបព្រៃឆ្នាំ២០០៦ បង្ហាញថា ក្នុងដែនសម្បទានទាំងមូលមានព្រៃពាក់កណ្ដាលស្រោង ចំនួន៩៧២ហិកតា ស្មើនឹង ៤៧.៤១ភាគរយ ព្រៃល្បោះចំនួន ១០៧៦ហិកតា ស្មើនឹង ៥២.៤៩ភាគរយ និងដីគ្មានគំរបព្រៃចំនួន ២ហិកតា ស្មើនឹង ០.១០ភាគរយ ។ ឈើភាគច្រើន ស្ថិតក្នុងអំបូរ *Diptero carpaceae* ជាឈើដែលមានតំលៃពាណិជ្ជកម្ម។ ដោយឡែកចំពោះប្រភេទឈើ ប្រណិតមានមួយចំនួនដូចជាៈ ប្រាំតំឡឹង *(Combretaceae)* បេង *(Caesalpiniaceae)* គ្រញូង *(Ebenaceae)* ធ្នង់ *(Papilionaceae)* នាងនួន *(Papilionaceae)* និងក្រញូងនៅមានវត្តមានតិចតួច បំផុតសំរាប់តំបន់នេះ។ ចំណែកឯ តាត្រាវ *(Loganiaceae)* គ្រើល *(Anacardiaceae)* អង្កត់ខ្មៅ *(Ebenaceae)* ឈើខ្មៅ *(Ebenaceae)* យើងពុំសង្កេតឃើញមានវត្តមាន នៅក្នុងតំបន់នោះទេ។ ប្រភេទឈើ ដែលប្រទះឃើញមាននៅក្នុងតំបន់ដីសម្បទានរ៉ែនេះមានដូចជាៈ

| ឈ្មោះក្នុងស្រុក | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអំបូរ |
|---|---|---|
| ស្រឡៅ | *Lagerstroemia Calyculata* | |
| កកោះ | *Sindora cochinchinensis* | *Caesalpiniaceae* |
| ឈ្លីក | *Terminalia tomentosa* | *Combretaceae* |
| ពពូល | *Vitex sp* | *Verbenaceae* |
| សុក្រម | *Xylia dolabriformis* | *Mimosaceae* |
| ក្ទាវ | *Adina cordifolia* | *Dipterocarpaceae* |
| ត្បូង | *Dipterocarpus tuberculatus* | *Dipterocarpaceae* |
| ស្រល់ | *Poducarpus cupressina* | *Podocarpaceae* |
| ច្រម៉ាស់ | *Vatica astrotricha* | *Dipterocarpaceae* |
| កណ្ដោល | *Careya sphaerica* | *Myrtaceae* |
| ព្រីង | *Eugenia sp.* | *Myrtaceae* |
| ប្រហូស | *Garcinia ferrea* | *Guttiferes* |

| | | |
|---|---|---|
| ត្រមូង | *Garcinia schomburghiana* | *Gutiiferes* |
| ក្រាយ | *Kayea engeniafolia* | *Guttiferes* |
| ស្មាក្របី | *Knema corticosa* | *Myristicaceae* |
| ធ្នូក | *Parinarium annamensis* | *Rosaceae* |
| ស្វាយព្រៃ | *Swintonia pierri* | *Anacardiaceae* |
| ធ្វឹក | *Shorea obtusa* | *Dipterocarpaceae* |
| ឃ្លាស (ក្បៀស) | *Memecylon edule* | *Melastomaceae* |
| ល្ងៀង | *Cratoxylum formosum subsp* | *Guttiferes* |
| គាឡាត់ | *Canarium album* | *Burseraceae* |
| ភ្លូបាត | *Dillenia hookeri* | *Dilleniaceae* |
| ញ័រព្រៃ (ញរធំ) | *Morinda tomenta* | *Rubiaceae* |
| ស្ដៅ | *Azadirachta indica* | *Meliaceae* |
| កន្ទួតព្រៃ | *Phyllanthus emblica* | *Euphorbiaceae* |
| ពពាលខែ | *Alstonia scholaris* | *Apocynaceae* |

Source of families and scientific names: National priority tree species workshop, Cambodia Tree Seed Project/DANIDA, 2000.

**១៣៥.** ដោយផ្អែកលើការអង្កេត និងវាយតំលៃទៅលើប្រភេទព្រៃបង្ហាញថា (១) ប្រភេទព្រៃល្បោះ ស្រទាប់ទី១ មានកំពស់ពី៩-១៤ម និងស្រទាប់ទី២ មានកំពស់ពី៥-៨ម។ រីឯរុក្ខជាតិថ្នាក់ក្រោម ជាស្មៅព្រិច ស្បូវ និងកូនឈើតូចៗ ហើយមានសភាពស្ងួតខ្លាំងនៅរដូវប្រាំង ដែលអាចងាយនឹងបង្កអោយមានភ្លើងឆេះ និង (២) ព្រៃពាក់កណ្ដាលស្រោង ស្រទាប់ទី១ មានកំពស់ពី១០-១៨ម និងស្រទាប់ទី២ មានកំពស់ពី ៨-១០ម។ រីឯរចនាសម្ព័ន្ធថ្នាក់ក្រោមមានប្រភេទកូនឈើតូចៗ និងស្មៅតិចតួច។

**១៣៦.** នៅក្នុងព្រៃពាក់កណ្ដាលស្រោង ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង៥០ស.មឡើង គិតជាមធ្យម មាន៦ដើមក្នុង១ហិកតា។ ដូច្នេះនៅលើផ្ទៃដីព្រៃពាក់កណ្ដាលស្រោងចំនួន ៩៧២ហិកតា ឈើដែលមានអង្កត់ផ្ចិតធំជាង៥០ស.មឡើង មានចំនួនសរុប៥៨៣២ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩ ស.ម គិតជាមធ្យមមាន២៦ដើមក្នុង១ហិកតា។ ដូច្នេះលើផ្ទៃព្រៃពាក់កណ្ដាលស្រោងចំនួន ៩៧២ហិកតា ឈើដែលមានអង្កត់ផ្ចិតពី៣០-៤៩ស.ម មានចំនួនសរុប២៥២៧២ដើម។ ចំពោះដង់ស៊ីតេឈើដែលមាន អង្កត់ផ្ចិតពី ១០-២៩ គិតជាមធ្យមមាន៦៧ដើមក្នុង១ហិកតា។ ដូច្នេះ នៅលើផ្ទៃដីព្រៃពាក់កណ្ដាលស្រោងចំនួន ៩៧២ ហិកតា ឈើដែលមានអង្កត់ផ្ចិតពី១០-២៩ មានចំនួនសរុប ៦៥១២៤ដើម។ ចំណែកឯ ដង់ស៊ីតេឈើដែលមាន

Draft

អង្កត់ផ្ចិតពី៥-៩ស.ម គិតជាមធ្យមមាន១០៧ដើមក្នុង ១ហិកតា។ ដូច្នេះ នៅលើផ្ទៃដីព្រៃពាក់កណ្តាលស្រោង ចំនួន ៩៧២ហិកតា ឈើដែលមានអង្កត់ផ្ចិតពី៥-៩ស.ម មានចំនួនសរុប ១០៤០០៤ដើម។ គំរបព្រៃក្នុងតំបន់ នេះមានជាមធ្យម២០ភាគរយ នៃផ្ទៃដីព្រៃពាក់កណ្តាលស្រោងសរុប។

**១៣៧.** នៅក្នុងព្រៃល្បោះ ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតធំជាង៥០ស.មឡើង ក្រុមការងារពុំសង្កេតឃើញ មាននៅក្នុងតំបន់សម្បទានទេ។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី៣០-៤៩ស.ម គិតជាមធ្យមមាន១៣ ដើមក្នុង១ហិកតា។ ដូច្នេះលើផ្ទៃព្រៃល្បោះចំនួន ១០៧៦ហិកតា ឈើដែលមានអង្កត់ផ្ចិតពី ៣០-៤៩ស.ម មានចំនួនសរុប១៣៩៨៨ដើម។ ចំពោះដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី១០-២៩ គិតជាមធ្យមមាន៦៥ ដើមក្នុង១ហិកតា។ ដូច្នេះលើ ផ្ទៃដីព្រៃល្បោះចំនួន ១០៧៦ហិកតា ឈើដែលមានអង្កត់ផ្ចិតពី១០-២៩ មាន ចំនួនសរុប ៦៩៩៤០ដើម។ ចំណែកឯ ដង់ស៊ីតេឈើដែលមានអង្កត់ផ្ចិតពី៥-៩ស.ម គិតជាមធ្យមមាន១១៥ ដើមក្នុង ១ហិកតា។ ដូច្នេះ នៅលើផ្ទៃដីព្រៃល្បោះចំនួន ១០៧៦ហិកតា ឈើដែលមានអង្កត់ផ្ចិតពី៥-៩ស.ម មានចំនួនសរុប ១២៣៧៤០ដើម។ គំរបព្រៃក្នុង តំបន់នេះមានជាមធ្យម១៦ភាគរយនៃផ្ទៃដីព្រៃល្បោះសរុប។

**១៣៨.** ជាការពិតណាស់អន្តរកម្មរវាងជីវៈចំរុះនៅក្នុងតំបន់មួយ ស្តែងចេញនូវភាពខុសប្លែកគ្នាពីសារពាង្គ កាយមួយទៅសារពាង្គកាយមួយទៀត។ វត្តមាននៃប្រភេទសត្វដែលរស់នៅក្នុងព្រៃក៏មានភាពខុសប្លែកគ្នាពី តំបន់មួយទៅតំបន់មួយដែរ ដោយអាស្រ័យលើលក្ខខ័ណ្ឌចំណីអាហារ ទីជំរក និងមជ្ឈដ្ឋាននៃការរស់នៅ។ តាមដំណើរការអង្កេត (សំរ៉ែក ដានជើង និងលាមក) និងការសំភាសន៍មួយប្រជាជនដែលរស់នៅក្បែរទី នោះបានអោយដឹងថា នៅក្នុងតំបន់សម្បទាននេះគេប្រទះឃើញមានវត្តមានសត្វឈ្លូស ស្វាគ្រប់ប្រភេទ ពស់ ជ្រូកព្រៃ ទន្សាយ កំប្រុក ត្រកួន ក្តាន់ព្រៀង ប្រមាំ រញី អណ្តើក កន្ធាយ ទោច ជ្រូកពោន។ល។ តាមរយៈការសាកសួរប្រជាជនដែលរស់នៅតំបន់ដដែលនោះក៏បានអោយដឹងផងដែរ ថាប្រភេទសត្វចតុប្បាទ ធំៗ ពុំមានវត្តមានឆ្លងកាត់នៅក្នុងតំបន់នេះទេដូចជាៈ អន្ទ្បោង ខ្ទីង ដំរី ខ្លាឃ្មុំ ខ្លារខិន ខ្លាដំបង។ល។

**១៣៩.** ចំពោះសត្វស្លាបដែលក្រុមសិក្សាសង្កេតឃើញ ដោយបង្ហាញពីវត្តមានសត្វតាមរយៈ ដានជើង សំរ៉ែក និងលាមក សង្កេតឃើញមានដូចជាៈ មាន់ព្រៃ គុក ចាបទ្រូងលឿង ទទារ លលក ចាប ត្រសេះ កេងកង ប្រវាំង ក្រួចអឹត សារិកាកែវ កូនលោក ទាព្រៃ ទាវ។ល។ តាមរយៈការសាកសួរប្រជាជនដែលរស់នៅ ក្បែរតំបន់សម្បទានបានអោយដឹងថា មិនឃើញមានសត្វស្លាបធំៗទេ។

**១៤០.** ចំពោះមច្ឆាជាតិនៅក្នុងតំបន់សម្បទានរ៉ែមិនសំបូរប្រភពទឹកស្រទាប់លើទេ ពោលគឺមានតែអូរ ដែល ស្ថិតនៅក្បែរបណ្តោយព្រំខាងកើត និងខាងលិចរបស់ដីសម្បទាន និងដៃអូរមួយចំនួននៃអូរខ្លិកខ្លក់ ដែលហូរកាត់ តំបន់ដីសម្បទាន ពីទិសខាងជើងទៅខាងកើត ត្បូង និងលិចប៉ុណ្ណោះ។ តាមការសាកសួរពីប្រជាពលរដ្ឋនៅ ក្នុងតំបន់បញ្ជាក់ថា ពួកគាត់ធ្លាប់នេសាទបាននូវប្រភេទត្រីមួយចំនួន (ទាំងប្រភេទត្រីស និងត្រីខ្មៅ) នៅក្នុង តំបន់នោះ។ ប្រភេទត្រីសំខាន់ៗ ដែលពួកគាត់ធ្លាប់នេសាទមានដូចជាៈ (១) **ត្រីសៈ** ត្រីរៀលអង្កាម

Draft

(Henicorthynechus lobatus), ត្រីចង្វារនោង (Luciosoma setigerum), ត្រីខ្មាន់ (*Hampala macrolepidota*), ត្រីគល់ព្រេច (Neolissochilus Blanic) **និង (២) ត្រីខ្មៅ:** ត្រីផ្ទក់ (Channa Striata), ត្រីរស់ (*Channa Striata*), ត្រីអណ្តែងរាំង (Clarias nieu hofii), ត្រីខ្សាន (Channa Gachua) (ឧបសម្ព័ន្ធ៧-២:រូបត្រីដែលប្រជានេសាទនៅក្នុងអន្លុងចុងក្រោយមួយ ចម្ងាយប្រមាណ០៨គ.ម ពីរណ្តៅរ៉ែទី-១)។

## គ- ការអភិវឌ្ឍន៍សេដ្ឋកិច្ច

**១៤១.** ក្រៅពីក្នុងទីរួមខេត្ត ដីដែលនៅតាមសងខាងបណ្តោយផ្លូវ (ខេត្តក្រចេះ-ស្រុកសំបូរ) និងផ្លូវជាតិលេខ ៧ ភាគច្រើនគឺជនបទ។ ការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចក្នុងតំបន់នេះ (តាមទីប្រជុំស្រុក) មានលក្ខណ:ប្រហាក់ប្រហែលគ្នា គឺការប្រកបរបរកសិកម្ម (ការធ្វើស្រែ និងដំណាំរួមផ្សំ) និងចូលព្រៃរុករកផល-អនុផល ព្រៃឈើ លើកលែងតែ ភូមិត្រួនមួយទេ ដែលប្រជាជនប្រកបមុខរបរជីករ៉ែមាស។

**១៤២.** សេដ្ឋកិច្ចក្នុងតំបន់មានលក្ខណ:ជាសេដ្ឋកិច្ចជនបទ លើកលែងតែទីរួមខេត្តចេញ ដែលការប្រកបរបរមានទ្រង់ទ្រាយពាណិជ្ជកម្ម។ ចំណូលប្រចាំឆ្នាំរបស់គ្រួសារក្នុងសហគមន៍ មានលក្ខណ:ផ្សេង១គ្នាអាស្រ័យទៅនឹងការប្រកបមុខរបររបស់គ្រួសារនីមួយ១។ ការវាយតំលៃអំពីភាពក្រីក្របានបង្ហាញថា អាត្រានៃភាពក្រីក្រនៅក្នុងខេត្តក្រចេះមាន ៣៨.៦០ភាគរយ (៩៧.៨៣ពាន់នាក់) លើចំនួនប្រជាជនសរុប ២៨៥.២៥១នាក់ ដែលភាគច្រើនរស់នៅជនបទ (ផែនទីភាពក្រីក្ររបស់កម្មវិធីស្បៀង អង្គការសហប្រជាជាតិ ឆ្នាំ២០០៥-២០០៦ និងប្រព័ន្ធទិន្នន័យសហគមន៍ឆ្នាំ២០០៤)។ ចំនួនអ្នកមិនចេះអក្សរសរុបមាន ៣៨.៥៩១៣នាក់ នៅទូទាំងខេត្តក្រចេះ។

**១៤៣.** គួរបញ្ជាក់ថា លទ្ធភាពនៃការប្រើប្រាស់សេវាសាធារណ: (ការផ្គត់ផ្គង់អគ្គីសនី ទឹកស្អាត គមនាគមន៍ សេវាអប់រំ និងសុខាភិបាល) នៅក្នុងសហគមន៍ទាំងនេះស្ថិតនៅក្រោមបន្ទាត់នៃតម្រូវការ បើប្រៀបធៀបជាមួយនឹងគ្រួសារសហគមន៍នៅក្នុងតំបន់ដទៃទៀតរបស់ប្រទេសកម្ពុជា (តំបន់ទីប្រជុំជនខេត្ត)។ ការសិក្សាបានបង្ហាញអោយឃើញថា អ្នកភូមិក្នុងឃុំក្បាលដំរី និងឃុំសំបុក ពុំបានទទួលការផ្គត់ផ្គង់អគ្គីសនីជាមូលដ្ឋានទេ។ ចំពោះបណ្តាញអគ្គិសនីនៅក្នុងតំបន់នោះគឺពុំទាន់មាននៅឡើយ គឺមានត្រឹមតែការប្រើប្រាស់អាគុយភាគច្រើន ប្រើចង្កៀងប្រេងកាត និងប្រើម៉ាស៊ីនភ្លើងតិចតួចសំរាប់បំភ្លឺនៅពេលយប់។ រីឯការចំអិនអាហារវិញ គឺពួកគាត់ប្រើអុសដែលរកបានពីព្រៃនៅក្បែរ១ភូមិ ឬទៅរកពីព្រៃដែលមានចំងាយ ១-២គីឡូម៉ែត្រពីភូមិ។

**១៤៤.** ការប្រើប្រាស់ទឹកស្អាតក៏នៅមានកំរិត ជាក់ស្តែងនៅក្នុងភូមិនិមួយ១នៃឃុំក្បាលដំរី និងឃុំសំបុក ក្នុងតំបន់គំរោង ពុំមានអណ្តូងស្នប់ប្រើប្រាស់គ្រប់គ្រាន់ទេ ភាគច្រើនគឺពួកគាត់ប្រើប្រាស់ទឹកអណ្តូងលូ អណ្តូងជីក

ដៃ ទឹកអូរ ស្ទឹងសំរាប់បរិភោគ និងប្រើប្រាស់ផ្សេងៗ ដែលនៅរដូវវស្សា ទឹកសំរាប់ប្រើប្រាស់ពុំមានបញ្ហាចោទទេ ដោយប្រជាពលរដ្ឋខ្លះប្រើទឹកអណ្តូងស្នប់ និងខ្លះទៀតត្រង់ទឹកភ្លៀងមកប្រើ ប៉ុន្តែនៅរដូវប្រាំងវិញបងប្អូនប្រជាពលរដ្ឋជួបប្រទះការខ្វះខាតទឹក ដោយសារអណ្តូងជីកដៃ អូរមួយចំនួនធំត្រូវបានរីងស្ងួត ហើយអណ្តូងលូភាគច្រើន និងអណ្តូងស្នប់មួយចំនួនមានបរិមាណទឹកតិច ដូច្នេះត្រូវបង្ខំចិត្តប្រើប្រាស់ទឹកមិនស្អាតដែលបានមកពីប្រភព មួយចំនួនដូចជា អូរ និងស្ទឹងជាដើម។ លើសពីនេះទៅទៀត ចំពោះភូមិត្រួនដែលជាភូមិឧបសម្ព័ន្ធភូមិពោធិ៍ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ស្រាវជ្រាវរុករករ៉ែមាសរបស់ក្រុមហ៊ុន ពុំមានទឹកស្អាតប្រើប្រាស់ទេ គឺពួកគាត់បានទិញទឹកប្រើប្រាស់ដោយ ៣០លីត្រតំលៃ២០០០រៀល (ប្រភពទឹកទន្លេមេគង្គ)។

១៤៥. ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើន គឺប្រើប្រាស់ផ្លូវជាតិលេខ៧ (ទីរួមខេត្តក្រចេះ-ខេត្តស្ទឹងត្រែង-ខេត្តរតនះគីរី) និងផ្លូវ(ខេត្តក្រចេះ-ស្រុកសំបូរ) ដែលជាផ្លូវយ៉ាងសំខាន់នៅក្នុងតំបន់នេះ។ រីឯផ្លូវដែលតភ្ជាប់ផ្លូវជាតិទៅនឹងតំបន់សម្បទានរ៉ែនោះជាផ្លូវលំ។ ចំណែកឯផ្លូវ ដែលតភ្ជាប់ពីផ្លូវទាំងនេះទៅសហគមន៍ពួកគាត់ភាគច្រើនជា ផ្លូវលំ ក្នុងនោះមួយចំនួនជាផ្លូវក្រាលគ្រួសក្រហម ដែលកសាងដោយគំរោងអភិវឌ្ឍន៍ឃុំ ហើយមួយចំនួនទៀតជា ផ្លូវរទេះ ឬផ្លូវលំដើរដោយជើង។ ផ្លូវទាំងនេះនៅក្នុងរដូវវស្សាមានសភាពទ្រុឌទ្រោមពិបាកធ្វើដំណើរ។

## ស្ថានភាពផ្ទះ និងទ្រព្យសម្បត្តិគ្រួសារ

១៤៦. តាមលទ្ធផលនៃការសិក្សា ក៏ដូចជាការអង្កេតផ្ទាល់ឃើញថាប្រជាជននៅក្នុងភូមិពាក់ព័ន្ធមានជីវភាពរស់នៅជាមធ្យម និងលទ្ធភាពសង់លំនៅដ្ឋានមានស្ថានភាពប្រហាក់ប្រហែលគ្នា។ ដោយសារតែការរស់នៅរបស់ប្រជាជននៅភូមិទាំងអស់នោះស្ថិតនៅតំបន់ដែលធ្លាប់សំបូរទៅដោយឈើដែលមានសក្តានុពល អាចអោយពួកគាត់ខ្លះមានលទ្ធភាពក្នុងការទាញយកឈើ និងសន្សំរក្សាទុកដើម្បីសាងសង់លំនៅដ្ឋានបានសមរម្យបើយើងប្រៀបធៀបនឹងលំនៅស្ថានជនបទភាគច្រើននៅក្នុងប្រទេសកម្ពុជាផ្សេងទៀត ដែលប្រជាជនមិនបានទទួលផលពីប្រភពធនធានធម្មជាតិដូច្នេះ។ ថ្វីត្បិតតែការសាងសង់ផ្ទះរបស់ពួកគាត់ធ្វើទៅតាមលទ្ធភាព និងចំនួនសមាជិកនៃគ្រួសារនិមួយៗក៏ដោយភាគច្រើនផ្ទះរបស់ពួកគាត់ធ្វើអំពីឈើប្រក់ក្បឿង(នៅតាមដងផ្លូវក្នុងឃុំ) ឬសង់អំពីឈើប្រក់សង្ក័សី/ស៊ីប្រូ និងមួយចំនួនទៀតធ្វើអំពីឈើប្រក់ស្លឹក។ ទិន្នន័យដែលទទួលបានពីស្មៀនឃុំបង្ហាញថានៅក្នុងឃុំក្បាលដំរី មានផ្ទះឈើសង់ផុតពីដីជញ្ជាំងក្តារនិងមានដំបូលប្រក់សង្កសី មានចំនួន ៣២៨ផ្ទះ ផ្ទះដំបូលប្រក់ក្បឿងមានចំនួន ១៦៨ផ្ទះ ផ្ទះប្រក់ស្លឹកមានចំនួន ៤០២ផ្ទះ និងផ្ទះថ្មល្វែងមានចំនួន ១ល្វែង។ ចំណែកឃុំសំបុក មានផ្ទះឈើសង់ផុតពីដីជញ្ជាំងក្តារនិងមានដំបូលប្រក់សង្កសី មានចំនួន ៣២១ផ្ទះ ផ្ទះដំបូលប្រក់ក្បឿង មានចំនួន ៤០៤ផ្ទះ និងផ្ទះដំបូលប្រក់ស្លឹកមានចំនួន ៦២៨ផ្ទះ។ ផ្ទះដែលតូចមានទំហំ ១៥ម² សង់ផ្ទាល់ដី និង ផ្ទះដែលមានទំហំធំ គឺចាប់ពី ៤០ម²-៧០ម² សង់ផុតពីដីកំពស់ពី ២ម-៣ម។

## ការគ្រប់គ្រង និងកម្មសិទ្ធិដីធ្លី

១៤៧. បើតាមសំដីរបស់លោកមេឃុំ និងប្រជាពលរដ្ឋមួយចំនួននៅក្នុងឃុំក្បាលដំរីថា ពីដើមឡើយភូមិសុទ្ធតែ ជនជាតិភ្នងដែលមានកំណើតតាំងពីដូនតាមកម្លេះ។ ដោយសារលំហូរចូលនៃអ្នកស្រុកដែលរស់នៅក្នុងតំបន់ផ្សេងដើម្បីមកកាប់ឈើ និងជីកយកមាសបានជំរុញអោយអ្នកភូមិមួយចំនួនបង្ខំចិត្តចាកចោលភូមិរត់ទៅនៅក្នុងព្រៃ ហើយមួយចំនួនទៀតបានប្រែក្លាយជីវភាព និងរបៀបរស់នៅរបស់ខ្លួនដូចទៅនឹងប្រជាជនខ្មែរដែរ។ បច្ចុប្បន្ននេះអ្នកភូមិនៅក្នុងតំបន់នេះមានដីលំនៅដ្ឋានជាមធ្យម ១០០ម៉ែត្រក្រឡា (២០មx៥០ម) ក្នុងមួយគ្រួសារ។ តែភាគច្រើនក្នុងចំណោមពួកគាត់ពុំមានលិខិតបញ្ជាក់កម្មសិទ្ធិច្បាស់លាស់នៅឡើយទេ គឺមានត្រឹមតែលិខិតកាន់កាប់បណ្តោះអាសន្ន ដែលចេញដោយអាជ្ញាធរភូមិឃុំតែប៉ុណ្ណោះ។ ដោយឡែក ចំពោះដីស្រែវិញជាមធ្យមគឺកន្លះហិកតាក្នុងមួយគ្រួសារ និងដីចំការវិញជាមធ្យមមាន ១ហិកតា ក្នុងមួយគ្រួសារ។ ចំណែកប្រជាជនដែលរស់នៅក្នុងឃុំសំបុកភាគច្រើនជាជនជាតិខ្មែរ មានជនជាតិភ្នង និងមីលតិចតួច។

## ប្រភពទឹកសំរាប់ប្រើប្រាស់:

១៤៨. ទឹកអណ្តូងស្នប់ គឺជាប្រភពទឹកដ៏សំខាន់សំរាប់ប្រជាជននៅក្នុងតំបន់នេះបរិភោគ និងប្រើប្រាស់សំរាប់ សត្វចិញ្ចឹមតាមលក្ខណៈគ្រួសារ។ អ្នកភូមិភាគច្រើនប្រើប្រាស់អណ្តូងស្នប់ (ឧបត្ថម្ភដោយអង្គការOxfam និង GTZ) ព្រោះមានអនាម័យគ្រប់គ្រាន់ ដោយឡែកមានប្រជាជនខ្លះគាត់ប្រើប្រាស់រយ្លុងជីកដៃដែលនៅក្បែរផ្ទះរបស់គាត់ ក្រុមការងារអង្កេតឃើញថា ការប្រើប្រាស់ពុំមានអនាម័យគ្រប់គ្រាន់នៅឡើយទេ ដោយសារពួកគាត់ពុំមានលទ្ធភាពធ្វើជាអណ្តូងល្អ ដូច្នេះ នៅរដូវវស្សាងាយស្រួលអោយទឹកក្រខ្វក់ដែលនាំដោយទឹកភ្លៀងហូរចាក់ ទៅក្នុងអណ្តូង។ បើទោះជាយ៉ាងនេះក្តី ទឹកអូរនៅតែដើរតួនាទីសំខាន់សំរាប់ ផ្គត់ផ្គង់ដល់សកម្មភាពដាំដុះផ្សេងៗ និងរបរជីករ៉ែមាសរបស់អ្នកភូមិនៅតំបន់អូរខ្លិកខ្លក់ដដែល។

## កំលាំងអូសទាញ និងការចិញ្ចឹមសត្វ

១៤៩. គោ-ក្របីត្រូវបានគេចាត់ទុកថាជាកំលាំងអូសទាញដែលសំខាន់ជាងគេ សំរាប់បំរើបំរាស់នៅក្នុងការធ្វើស្រែ-ចំការ។ បើគិតជាមធ្យមក្នុងមួយគ្រួសារយ៉ាងហោចណាស់ក៏មានក្របី ឬគោមួយនឹមសំរាប់ជាកំលាំងអូសទាញដែរ។ លើសពីនេះទៅទៀត ក៏មានអ្នកភូមិមួយចំនួនកំពុងប្រើប្រាស់គោយន្តសំរាប់ជាកំលាំងអូសទាញជំនួសកំលាំងគោក្របីដែរជាពិសេសនៅភូមិស្រែស្បូវ ភូមិតាណឹង ឃុំក្បាលដំរី និងភូមិសំបុក ភូមិក្បាលជួរ ភូមិកាកុត ឃុំសំបុក។ ចំពោះយុទ្ធសាស្ត្រនៅក្នុងការចិញ្ចឹមសត្វពាហនៈរបស់ ប្រជាពលរដ្ឋនៅក្នុងតំបន់នេះពុំទាន់បានល្អនៅឡើយទេ។

## ចំណេះដឹង និងការអប់រំ

**១៥០.** ដោយសារភាពមមាញឹកនៅក្នុងការងារស្រែចំការ យើងមើលឃើញថាមេគ្រួសារភាគច្រើនទទួលបានការអប់រំជាមូលដ្ឋានតិចតួចបើប្រៀបធៀបទៅនឹងប្រជាជននៅតំបន់ផ្សេង។ ការចុះឈ្មោះចូលរៀនរបស់កុមារដែលដល់អាយុចូលរៀនមានកំណើនឡើងគួរអោយកត់សំគាល់ក្នុងរយៈកាល ៣ ទៅ៤ឆ្នាំចុងក្រោយនេះ។ ដោយសារ ប្រជាពលរដ្ឋកាន់តែយល់ដឹងអំពីសារៈសំខាន់ក្នុងការសិក្សារបស់កុមារ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដែលបានកំពុងយកចិត្តទុកដាក់ខ្លាំងនៅក្នុងយុទ្ធសាស្ត្រដែលជំរុញ អោយកុមារបានចូលរៀន ១០០ភាគរយក្នុងកំរិតបឋមសិក្សា។ បើទោះជាយ៉ាងនេះក្តីយើងសង្កេតឃើញថា សាលារៀនថ្នាក់បឋមនៅក្នុងតំបន់នេះមិនទាន់បំពេញតំរូវការនៃកំណើនរបស់កុមារនៅឡើយទេ។ ចំពោះថ្នាក់លើសពីបឋមសិក្សា និងអនុវិទ្យាល័យវិញ អ្នកភូមិត្រូវបញ្ជូនកូនអោយទៅរៀននៅទីរួមស្រុកសំបូរ ឬទីរួមខេត្តក្រចេះ។ អ្នកដែលមានឱកាសអោយកូនទៅរៀននៅទីរួមស្រុក ឬទីរួមខេត្ត មានមិនច្រើននោះទេ ដោយសារពួកគេភាគច្រើនជាប់រវល់នៅក្នុងសកម្មភាពបង្កបង្កើនផលក្នុងគ្រួសារ និងណាមួយចំងាយពីផ្ទះ ទៅសាលាមានចំងាយឆ្ងាយ។ បើគិតពីឃុំក្បាលដំរីទៅស្រុកសំបូរមានចំងាយប្រមាណជា ៣៥គីឡូម៉ែត្រ ឬ ៥៥-៦០គីឡូម៉ែត្រទើបដល់ទីរួមខេត្ត ចំណែកឯ ឃុំសំបុកមានចំងាយប្រមាណជា១២គីឡូម៉ែត្រទេពីទីរួមខេត្ត។

## សុខភាព និងអនាម័យ

**១៥១.** នៅក្នុងរយៈកាលបីឆ្នាំចុងក្រោយនេះ អ្នកភូមិហាក់ដូចបានយល់កាន់តែច្បាស់អំពីសារៈសំខាន់នៅក្នុងការស្វែងរកសេវាសុខភាពដ៏ត្រឹមត្រូវនៅពេលដែលគាត់មានជំងឺដង្កាត់ផ្សេងៗ។ ពីមុនដោយសារស្រុកនេះជាស្រុកព្រៃ ហើយសេវាសុខភាពសាធារណៈពុំទាន់មាននៅឡើយនោះ អ្នកភូមិនិយមជឿជាក់លើថ្នាំខ្មែរ និងទទួលយកការព្យាបាលបែបបូរាណនៅពេលដែលពួកគាត់មានជំងឺដង្កាត់ផ្សេងៗ។ ចំពោះសេវាសុខាភិបាលវិញ ក្នុងឃុំក្បាលដំរី និងឃុំសំបុក ពុំទាន់មានមណ្ឌលសុខភាពនៅឡើយទេ មានត្រឹមតែប៉ុស្តិ៍សុខភាពតែមួយកន្លែងស្ថិតនៅក្នុងភូមិអូរតាណឹង ឃុំក្បាលដំរី។ ទោះបីជាយ៉ាងណាក៏ដោយ បើតាមការសាកសួរគឺមានឆ្មបបណ្តុះបណ្តាលនៅតាមភូមិនីមួយៗ។ ពេលមានមនុស្សឈឺត្រូវបញ្ជូនអ្នកជំងឺទៅព្យាបាលនៅមណ្ឌលសុខភាពឃុំអូរគ្រៀង ឬស្រុកសំបូរ ឬអាចដាក់ឡានយកទៅពេទ្យបង្អែកខេត្តតែម្តង ដែលមានចម្ងាយផ្លូវពីឃុំទៅស្រុកប្រមាណជា ៣៥គីឡូម៉ែត្រ ឬពីឃុំទៅខេត្តប្រមាណជា ៥៥-៦០គីឡូម៉ែត្រ។

## មធ្យោបាយធ្វើដំណើរ និងការដឹកជញ្ជូន

**១៥២.** ការធ្វើដំណើរ និងដឹកជញ្ជូននៅក្នុងតំបន់គំរោងភាគច្រើន គឺប្រើប្រាស់ផ្លូវជាតិលេខ៧ (ទីរួមខេត្តក្រចេះ-ខេត្តស្ទឹងត្រែង-ខេត្តរតនៈគីរី) និងផ្លូវ(ខេត្តក្រចេះ-ស្រុកសំបូរ) ដែលជាផ្លូវយ៉ាងសំខាន់នៅក្នុងតំបន់នេះ។



Draft

ទោះបីផ្លូវគមនាគមន៍ក្នុងតំបន់នេះ (ផ្លូវលំគ្រួសក្រហមទៅកាន់ភូមិផ្សេងៗ) មានការខូចខាត និងរអិល ដែលបណ្តាលមកពីទឹកភ្លៀងរដូវវស្សាលិច និង ហូរកាត់ដោយកន្លែងៗ។ ដោយហេតុថា ផ្លូវក្នុងតំបន់នេះមានការលំបាកខ្លាំងក្នុងការធ្វើដំណើរប្រជាជនភាគតិច ប្រើប្រាស់គង់ និងម៉ូតូជាមធ្យោបាយធ្វើដំណើរ និងធ្វើដំណើរដោយថ្មើរជើងភាគច្រើនពីភូមិមួយទៅភូមិមួយ ។

**លទ្ធភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិ**

១៩៣. នៅក្នុងតំបន់នេះក្រៅពីធនធានរ៉ែមាស ព្រៃពាក់កណ្តាលស្រោង និងព្រៃល្បោះហើយនោះ គេពុំឃើញមានធនធានធម្មជាតិ ដែលមានតំលៃដូចជាព្រៃឈើធំៗ និងបឹងទន្លេនោះទេ។ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនបានកំពុងរុករកប្រើប្រាស់ធនធានធម្មជាតិដែលមានតិចតួចនៅក្នុងតំបន់របស់ខ្លួន ដូចជាពួកគាត់អាចជីករកទំពាំងសំរាប់បរិភោគ និងមួយចំនួនតូចអាចលក់ដើម្បីជាចំនូលបន្ទាប់បន្សំ។ ក្រៅពីនេះប្រជាពលរដ្ឋអាចរកនេសាទត្រីតាមអូរខ្លិកខ្លក់ និងលើផ្ទៃដីលិចទឹកនារដូវវស្សា សំរាប់ជាម្ហូបអាហារបន្ថែមនៅក្នុងគ្រួសារ និងសំរាប់ដោះដូរ ជាអង្ករជាមួយអ្នកជិតខាងតែប៉ុណ្ណោះ។ ទោះជាធនធានរ៉ែមាសត្រូវបានគេដឹងថាមានសំបូរបែបនៅលើទឹកដី នៃតំបន់នេះក៏ដោយ ក៏បច្ចុប្បន្ននេះគេពុំសូវឃើញមានប្រជាពលរដ្ឋប្រកបរបរជីករករ៉ែមាស ដូចពីសម័យទសវត្ស ទី៨០-៩០ ទៀតឡើយ។

**ទិន្នផលកសិកម្ម**

១៩៤. ប្រជាជនក្នុងឃុំសំបុក និងឃុំក្បាលដំរីទាំងមូល ប្រភពចំណូលសំខាន់របស់ពួកគាត់គឺអាស្រ័យលើមុខរបរធ្វើស្រែចំការ (ទិន្នផលស្រូវទទួលបាន ១-២,៥តោនក្នុងមួយហិកតា) ចំពោះឃុំក្បាលដំរីស្រូវ០១គីឡូក្រាម អាចលក់បានតំលៃពី ៧០០-១០០០រៀល។ ចំណែកឯ ឃុំសំបុកស្រូវ០១គីឡូក្រាម អាចលក់បានតំលៃពី ៨០០-១១០០រៀល និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារមានដូចជា គោ ក្របី ជ្រូក មាន់ ទាជាដើម។ ការចិញ្ចឹមគោ-ក្របីរបស់ពួកគាត់ មិនត្រឹមតែទុកសំរាប់ប្រើប្រាស់ជាមធ្យោបាយអូសទាញក្នុងវិស័យកសិកម្មប៉ុណ្ណោះទេ ព្រមទាំងអាចលក់ដូរសំរាប់ដោះស្រាយ វិបត្តិសេដ្ឋកិច្ចក្នុងគ្រួសារថែមទៀតផង។ ដោយឡែក ជ្រូករស់០១គីឡូក្រាម អាចលក់បានតំលៃ ៥.០០០រៀល ឬតំលៃ ៦.៥០០រៀលក្នុងមួយគីឡូក្រាម ឯមាន់ និងទា អាចលក់បានតំលៃ ១៣.០០០-១៥.០០០រៀលក្នុងមួយគីឡូក្រាម។ ចំពោះគ្រួសារមួយចំនួនដែលអាស្រ័យតែលើមុខរបរធ្វើស្រែ ពុំមានស្បៀងអាហារហូបគ្រប់គ្រាន់ទេ មានឆ្នាំខ្លះគ្រួសារទាំងនោះខ្វះខាតស្បៀងរហូតដល់ទៅ ៣-៤ខែឯណោះ។

Draft

## ឃ- ធនធានសង្គម និងវប្បធម៌

១៥៥. ក្រុមការងារជាដំបូងបានធ្វើការសិក្សានៅឃុំក្បាលដំរីមានភូមិចំនួន ០៥ មានប្រជាជនសរុបចំនួន ១០៨៦ គ្រួសារ ស្មើនឹង ៥០០៨នាក់ ក្នុងនោះប្រជាជនចំនួន ២៥៦៦ នាក់ ជានារីភេទ។ ចំណែកឯ ឃុំសំបុក មានភូមិចំនួន ០៥ មានប្រជាជនសរុបចំនួន ១៥៩០គ្រួសារ ស្មើនឹង ៧៣២៨នាក់ ក្នុងនោះប្រជាជនចំនួន ៣៦០៩ នាក់ ជានារីភេទ។

**តារាង៥-៥: ស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០១០ ឃុំក្បាលដំរី ស្រុកសំបូរ**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋសរុប(នាក់) | ចំនួនស្រីសរុប (នាក់) |
|---|---|---|---|---|
| ១ | ស្រែស្បូវ | ២៣០ | ១១៤៦ | ៦៣៣ |
| ២ | អូរតាណឹង | ១៤២ | ៦៤៨ | ៣២៣ |
| ៣ | អូរចង្អប | ១៥៧ | ៧៧៦ | ៣៧៩ |
| ៤ | ស្រែត្រែង | ៣៦៧ | ១៦៧៨ | ៨២៧ |
| ៥ | អូរពោធិ៍ | ១៨៨ | ៧៦០ | ៤០៤ |
| **សរុបរួម** | | **១០៨៦** | **៥០០៨** | **២៥៦៦** |

* **<u>បញ្ជាក់</u>:** តាមការចុះសិក្សាបង្ហាញថា ទីតាំងដីសម្បទានដែលក្រុមហ៊ុន **XING YUAN KANNG YEAK Co., Ltd.** ស្នើសុំស្រាវជ្រាវរុករករ៉ែមាស មានជាប់ពាក់ព័ន្ធតែមួយភូមិទេគឺ ភូមិត្រូន (ជាភូមិឧបសម្ព័ន្ធភូមិអូរពោធិ៍) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ធ្វើអាជីវកម្មរុករករ៉ែមាសតែម្តង។

**តារាង៥-៦: ស្ថិតិប្រជាពលរដ្ឋឆ្នាំ ២០០៩ ឃុំសំបុក ស្រុកចិត្របុរី**

| ល.រ | ឈ្មោះភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាពលរដ្ឋសរុប(នាក់) | ចំនួនស្រីសរុប(នាក់) |
|---|---|---|---|---|
| ១ | សំបុក | ៧០២ | ៣១៧១ | ១៥៩០ |
| ២ | ក្បាលជួរ | ៣៩៣ | ១៨០៩ | ៨៦៩ |

| | | | | |
|---|---|---|---|---|
| ៣ | កាកុត | ២១១ | ១០៦៦ | ៥៤៣ |
| ៤ | ស្រែតាហែន | ១២១ | ៥៣៩ | ២១៩ |
| ៥ | បឹងរុន | ១៦៣ | ៧៤៣ | ៣៨៨ |
| **សរុបរួម** | | **១៥៥០** | **៧៣២៨** | **៣៦០៩** |

* **<u>បញ្ជាក់</u>:** តាមការចុះសិក្សាបង្ហាញថា ទីតាំងដីសម្បទានដែលក្រុមហ៊ុន **XING YUAN KANNG YEAK Co., Ltd.** ស្នើសុំស្រាវជ្រាវរុករករ៉ែមាស ពុំមានជាប់ពាក់ព័ន្ធនឹងភូមិទាំង០៥ខាងលើទេ។

**១៥៦.** លំនាំនៃការតាំងទីលំនៅរបស់ប្រជាជនមានលក្ខណៈជាជនបទៈ (១) ពួកគាត់រស់នៅអមតាមសងខាងផ្លូវលំក្រាលគ្រួសក្រហម និងអមតាមសងខាងផ្លូវជាតិលេខ៧ក្រាលកៅស៊ូ (២) ការតាំងលំនៅដ្ឋានជាលក្ខណៈ ប្រមូលផ្តុំនៅតាមភូមិក្នុងព្រៃ (ភាគច្រើនជាជនជាតិភ្នង) ដោយត្រូវធ្វើដំណើរដោយរម៉ូតូ ឬកង់តាមផ្លូវទេះ តូចចង្អៀត រអិល ជាប់ផុងដោយអន្លើៗពិបាកធ្វើដំណើរ និងត្រូវឆ្លងកាត់ព្រៃល្បោះដោយកន្លែង។ ក្នុងឃុំក្បាលដំរីនៃតំបន់គំរោងនេះមានវត្តមានជនជាតិភ្នងប្រមាណជា៦០-៦៥ភាគរយ ក្រៅពីនេះសុទ្ធតែជនជាតិខ្មែរ។ ចំណែកឯ ឃុំសំបុកមានវត្តមានជនជាតិភ្នងប្រមាណជា ២០ភាគរយ ក្រៅពីនេះសុទ្ធតែជនជាតិខ្មែរ។

**១៥៧.** តាមការសិក្សារបស់ក្រុមការងារលើប្រភពព័ត៌មានដែលទទួលបានពីមូលដ្ឋានបង្ហាញថា នៅក្នុងទីតាំងតំបន់គំរោងនេះ ពុំមានសំណាក ឬសំណង់ប្រាសាទប្រវត្តិសាស្ត្រទេ។